# បាតបាយ៉ា និងសៀវភៅដែលមានរូបភាព

ដោយ រីឆាឌ អិម រ៉មនី
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )









វាជាថ្ងៃមួយដែលមានខ្យល់បក់បោកនៅក្នុងប្រទេសម៉ុងហ្គោលី ។ បាតបាយ៉ាមានអាយុប្រាំបួនឆ្នាំកំពុងតែដើរទៅផ្ទះពីចំណតឡានបន្ទាប់ពីចេញពីសាលារៀន ។ គាត់បានឱបអាវរងាគាត់កាន់តែណែននៅកណ្ដាលខ្យល់បក់នោះ ។ សំណាងល្អ កន្លែងដែលគាត់រស់នៅគឺផ្ទះតាយាយគាត់នៅមិនឆ្ងាយទេ ។

« ជម្រាបសួរ ! » បាតបាយ៉ាបាននិយាយពេលគាត់ចូលមកខាងក្នុង ។

លោកយាយបានមានប្រសាសន៍ថា « ស្វាគមន៍ចៅ ។ យាយបានធ្វើឃូអូស៊ូខ្លះសម្រាប់ញ៉ាំសម្រន់ » ។

«អរគុណលោកយាយ ! » បាតបាយ៉ាបានឈោងយកនំក្ដៅៗមួយ ជានំផាយសាច់មានជាតិហឹរ ។

លោកតាបានមានប្រសាសន៍ថា « ចាំសិន ! កុំទាន់ញ៉ាំ ចាំពួកអ្នកផ្សព្វផ្សាយសាសនាមកដល់សិន ។ ពួកគេនឹងមកដល់ឆាប់ៗនេះហើយ » ។

បាតបាយ៉ាចូលចិត្តពេលពួកអ្នកផ្សព្វផ្សាយសាសនាពីសាសនាចក្ររបស់លោកតាលោកយាយមកលេង ។ គាត់តែងតែរៀនជាច្រើនពីពួកគេ ។ ប៉ុន្តែមានបញ្ហាតែមួយគត់ ។

« តើពួកគេនឹងសូមឲ្យខ្ញុំអានព្រះគម្ពីរមរមនទៀតឬ ? » បាតបាយ៉ាបានសួរ ។ « ការអានគឺពិបាកសម្រាប់ខ្ញុំ » ។

លោកយាយបានមានប្រសាសន៍ថា « នោះហើយជាមូលហេតុដែលពួកគេនឹងយកសៀវភៅមួយផ្សេងទៀតមកនៅថ្ងៃនេះ » ។

បាតបាយ៉ាបានសួរថា « សៀវភៅអ្វីទៅ ? »

លោកតាថា « ចៅនឹងឃើញ » ។

មិនយូរប៉ុន្មានពួកអ្នកផ្សព្វផ្សាយបានមកដល់ ។ ពួកគេបានទទួលទាននំផាយសាច់ដ៏ឆ្ងាញ់របស់លោកយាយជាមួយគ្នា ។ បន្ទាប់មកបាតបាយ៉ាបាននិយាយថា « លោកយាយប្រាប់ថាស៊ីស្ទើរមានសៀវភៅមួយក្បាលមកឲ្យខ្ញុំ » ។

ស៊ីស្ទើរហៃតស្ស៍បាននិយាយថា « ខ្ញុំគិតថាប្អូននឹងចូលចិត្តសៀវភៅនេះ ។ វាមានរូបភាពច្រើនណាស់ » ។

បាតបាយ៉ាបានមើលទៅក្របសៀវភៅ ។ វាសរសេរថា សៀវភៅរឿងព្រះគម្ពីរមរមន ។ រូបភាពនៅលើក្របសៀវភៅនោះបង្ហាញពីមនុស្សកំពុងសង់សំពៅ ។

បាតបាយ៉ាបាននិយាយថា « ខ្ញុំចាំពីរឿងនោះ ។ បុរសនោះមិនបានដឹងពីរបៀបសង់សំពៅទេ ។ ដូច្នោះគាត់បានអធិស្ឋាន ។ ហើយព្រះបានជួយគាត់ » ។

ស៊ីស្ទើរអែងយូយ៉ាបាននិយាយថា « ត្រឹមត្រូវហើយ ។ តើប្អូននឹងព្យាយាមអានសៀវភៅនេះទេ ? រួចហើយប្អូនអាចអធិស្ឋានដើម្បីដឹងថាតើអ្វីវាបង្រៀនពិតឬទេ » ។

បាតបាយ៉ាបានសន្យាថា « ខ្ញុំនឹងធ្វើវា » ។

នៅយប់នោះគាត់បានអានសៀវភៅដែលមានរូបភាពនោះ ។ គាត់បានអានរឿងអំពីសំពៅ ។ បន្ទាប់មកគាត់បានអធិស្ឋាន ។ គាត់បានគេងលក់ដោយគិតអំពីបុរសដែលសង់សំពៅនោះ និងរបៀបដែលព្រះបានជួយគាត់ ។

តាំងពីពេលនោះមក បាតបាយ៉ាបានអានរឿងមួយជារៀងរាល់យប់ ។ បន្ទាប់មក គាត់បានអធិស្ឋាន ។ ហើយរាល់យប់ គាត់បានគេងលក់ដោយគិតអំពីអ្វីដែលគាត់បានអាន ។

ពេលដែលពួកអ្នកផ្សព្វផ្សាយសាសនាជាស៊ីស្ទើរបានត្រឡប់មកវិញ ពួកគេបានបង្រៀនបាតបាយ៉ាបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។ បាតបាយ៉ាបានរៀនអំពីពួកព្យាការី ។ គាត់បានរៀនអំពីព្រះបញ្ញត្តិរបស់ព្រះ ។ គាត់បន្តទៅព្រះវិហារជាមួយលោកយាយនិងលោកតា ។ ហើយគាត់បានបន្តអាន និងអធិស្ឋាន ។

ថ្ងៃមួយបាតបាយ៉ាមានអ្វីមួយសំខាន់ដើម្បីប្រាប់លោកតាលោកយាយរបស់គាត់ ។ គាត់បាននិយាយថា « ពេលខ្ញុំអានរឿងនៅក្នុងសៀវភៅដែលមានរូបភាពនោះ ខ្ញុំមានអារម្មណ៍ល្អ ។ ពេលខ្ញុំអធិស្ឋាន ខ្ញុំមានអារម្មណ៍ថារឿងទាំងនោះពិត ។ ខ្ញុំគិតថា ខ្ញុំគួរតែទទួលបុណ្យជ្រមុជទឹក » ។

ថ្ងៃនេះ បាតបាយ៉ាជាសមាជិកនៃសាសនាចក្រ ។ គាត់អានបានកាន់តែល្អឡើងៗ ។ ហើយគាត់នៅតែអានព្រះគម្ពីរមរមនជារៀងរាល់យប់ ! ●

រូបភាពដោយ ខារ៉ែន ម៉ាក

តើពួកអ្នកផ្សព្វផ្សាយសាសនាបានជួយបាតបាយ៉ាដោយរបៀបណា ? តើនរណាបានជួយអ្នក ?